# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**សន្និបាត (២០២៣)**

# ឯកសារទស្សនាទាន
## ស្ដីពី
## ការគាំពារ និងអភិវឌ្ឍកុមារតូចតាមគ្រប់រូបភាព

ការវិនិយោគនៅឆ្នាំដំបូង នៃជីវិតរបស់កុមារ ត្រូវបានចាត់ទុកជាការវិនិយោគដ៏ឆ្លាតវៃបំផុត ដែលផ្ដល់នូវផលប្រយោជន៍យ៉ាងធំធេងដល់ការរីកម្រើនកោសិកាខួរក្បាលរបស់កុមារតូច សមត្ថភាពការសិក្សា សុខភាព អកប្បកិរិយា និងផ្ដល់ឱកាសជោគជ័យពេញមួយជីវិតរបស់ពួកគេ ដែលទាំងនេះយើងអាចធ្វើបានតាមរយៈកិច្ចគាំទ្របែបពហុវិស័យ។ បច្ចុប្បន្ននេះ ការបម្រែបម្រួលអាសធាតុ ជាវិបត្តិមួយដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់កុមារផងដែរ ដូចជា៖ ជាតិពុលក្នុងបរិយាកាសបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព និងការអភិវឌ្ឍកោសិកាខួរក្បាលរបស់កុមារ ដែលទាមទារត្រូវមានវិធានការ និងសកម្មភាពទប់ស្កាត់វិបត្តិនេះជាបន្ទាន់តាមរយៈកិច្ចអន្តរាគមន៍បែបពហុវិស័យ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ទៅលើការអភិវឌ្ឍកុមារតូច។

ការស្រាវជ្រាវវេជ្ជសាស្ត្របង្ហាញថា កុមារអភិវឌ្ឍប្រព័ន្ធប្រសាទយ៉ាងឆាប់រហ័សបំផុតក្នុងរយៈពេល ១០០០ថ្ងៃ ដំបូង នៃជីវិត។ ចាប់ពីថ្ងៃកកំណើតរហូតដល់អាយុក្រោម ៣ ឆ្នាំ គឺជាអំឡុងពេល ដែលមាតាបិតាត្រូវផ្ដល់អាហារូបត្ថម្ភឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យកោសិកាខួរក្បាលមានការលូតលាស់បានល្អ ពីព្រោះក្នុងដំណាក់កាលដំបូងនេះ កោសិកាខួរក្បាលកុមារមានការលូតលាស់យ៉ាងលឿនរហូតដល់ ៧០%។ កុមារអាយុ ៣ ឆ្នាំ កោសិកាខួរក្បាលមានការរីកចម្រើនរហូតដល់ ៨០% នៃខួរក្បាលរបស់មនុស្សធំ និងរហូតដល់ ៩០% នៅអាយុ ៥ ឆ្នាំ ដែលជាកត្តាកំណត់ដល់ការអភិវឌ្ឍពុទ្ធិបញ្ញា និងការបណ្ដុះបំណិនផ្សេងទៀត ដូចជា៖ បំណិនសង្គម ភាពក្លាហាន ភាពអំណត់ បំណិនទំនាក់ទំនងជាដើម ដែលដើរតួនាទីយ៉ាងសំខាន់សម្រាប់ការធានាជោគជ័យក្នុងជីវិតរបស់កុមារ។

# ក្របខណ្ឌការចិញ្ចឹមបីបាច់កុមារតូច

ក្របខណ្ឌចិញ្ចឹមបីបាច់កុមារតូច បានគូសបញ្ជាក់៖

- ហេតុផល នៃកិច្ចខិតខំ ដើម្បីលើកកម្ពស់សុខភាព សុខុមាលភាព និងមូលធនមនុស្សចាំបាច់ត្រូវចាប់ផ្តើមក្នុងឆ្នាំដំបូងៗ ចាប់ពីពេលមានផ្ទៃពោះរហូតដល់អាយុ ៣ ឆ្នាំ
- បញ្ហាប្រឈមសំខាន់ៗ មានចំពោះការចិញ្ចឹមបីបាច់ ការអប់រំ និងការអភិវឌ្ឍកុមារតូច
- វិធីសាស្ត្រជួយការពារកុមារតូច ឱ្យចាកផុតពីផលប៉ះពាល់អាក្រក់ និងលើកកម្ពស់ការអភិវឌ្ឍរាងកាយ ផ្នែកសង្គម-អារម្មណ៍ និងផ្នែកចំណេះដឹង
- យន្តការគាំទ្រដល់អ្នកថែទាំកុមារតូចដើម្បីផ្តល់សេវាគាំទ្រកុមារតូចឱ្យទទួលបានលទ្ធផលដូចការរំពឹងទុក។




គោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូច បានកំណត់ចក្ខុវិស័យ "**កុមារតូចទាំងអស់ចាប់ពីកកំណើតរហូតដល់អាយុក្រោម ៦ ឆ្នាំ ត្រូវទទួលបានសេវាគាំពារ និងអភិវឌ្ឍ ជាពិសេសកុមារតូចរងគ្រោះ កុមារតូចងាយរងគ្រោះ និងក្រខ្សត់ ស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**"។ ការយកចិត្តទុកដាក់ និងអន្តរាគមន៍ទាន់ពេលវេលាដល់កុមារក្នុងវ័យដំបូងតាមរយៈកម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូច បានកាត់បន្ថយមានចរិត «មជ្ឈត្តនិយម» (egocentrism)របស់កុមារ ដូចជា៖ (១) ខ្លួនឯងជាមនុស្ស សំខាន់ជាងគេ (២) អ្វីៗ ទាំងអស់ជារបស់ខ្លួន (៣) អ្នកដែលនៅជុំវិញខ្លួនត្រូវតែយកចិត្តទុកដាក់ទៅលើខ្លួន (៤) មិនយកចិត្តទុកដាក់ ឬ ផ្តល់តម្លៃដល់អ្នកដទៃ (៥) មិនសូវស្តាប់បង្គាប់ និងរឹងរូសជាដើម។

## ១. វឌ្ឍនភាពការគាំពារនិងអភិវឌ្ឍន៍កុមារតូច (ECCD progress)



## សុខភាព និងអាហារូបត្ថម្ភ

**និន្នាការ នៃស្ថានភាព អាហារូបត្ថម្ភ របស់កុមារតូច**




**និន្នាការ នៃអត្រា មរណៈភាព របស់កុមារតូច**




## កុមារអាយុ ៥ ឆ្នាំ ទទួលបានសេវាអប់រំគ្រប់រូបភាព




## វឌ្ឍនភាពសំខាន់ៗ ឆ្នាំ ២០២២ (key Progress in 2022)

- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច ចូលរួមថ្លែងសុន្ទរកថាក្នុងពិធីបើកសន្និសិទអន្តរជាតិថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក ស្តីពីការអភិវឌ្ឍកុមារតូច លើប្រធានបទ៖ Young Children in Crisis: Addressing the Impact of Covid-19, Climate Change and Environmental Degradation តាមប្រព័ន្ធបញ្ជូនរូបភាព និងសម្លេងពីចម្ងាយ
- ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ២០២២-២០២៦ បានទទួលការឯកភាពពីគណៈកម្មាធិការជាតិកាលពីខែមិថុនា ឆ្នាំ២០២២

- ផ្សព្វផ្សាយដាក់ឱ្យអនុវត្តផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច២០២២-២០២៦ ដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈអភិបាលរាជធានី ខេត្ត ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងមន្ត្រីជំនាញពាក់ព័ន្ធគ្រប់រាជធានី ខេត្ត
- ប្រកាសផ្សព្វផ្សាយដាក់ឱ្យអនុវត្តផែនការសកម្មភាពស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូច២០២៣-២០២៥ របស់ខេត្តក្រចេះ
- ដាក់ឱ្យដំណើរការទារកដ្ឋានប្រចាំសហគមន៍ចំនួន ៤ កន្លែង នៅខេត្តកំពង់ស្ពឺ និងបន្តសាងសង់ ៥ កន្លែងទៀតនៅខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម
- ចូលរួមធ្វើវាគ្មិនចែករំលែកបទពិសោធក្នុងសិក្ខាសាលាស្តីពីការអភិវឌ្ឍកុមារតូចបែបពហុវិស័យ(IECD) នៅប្រទេសម៉ុងហ្គោលី តាមប្រព័ន្ធបញ្ជូនរូបភាព និងសម្លេងពីចម្ងាយ
- ចូលរួមធ្វើជាវាគ្មិនក្នុងវេទិកា The Learning Exchange Forum on Southeast Asian Early Childhood Development Promotion (SEA-ECDP) and Workshop on Establishment of SEA–ECDP តាមប្រព័ន្ធបញ្ជូនរូបភាព និងសម្លេងពីចម្ងាយ
- ចូលរួមសន្និសីទពិភពលោកស្តីពីការគាំពារ និងអប់រំកុមារតូច (World Conference on ECCE) នៅប្រទេស Uzbekistan
- ចូលរួមសន្និសីទអន្តរជាតិប្រចាំឆ្នាំស្តីពីការអប់រំកុមារតូច ការថែទាំកុមារតូច ការអប់រំមាតាបិតា នៅប្រទេសឥណ្ឌូនេស៊ី
- រៀបចំទស្សនៈកិច្ចសិក្សាបែបពហុវិស័យសម្រាប់ការពាំគារ និងអភិវឌ្ឍកុមារតូច នៅខេត្តក្រចេះ
- រៀបចំកញ្ចប់អប់រំមាតាបិតាអំពីការបីបាច់ចិញ្ចឹមកុមារតូច និងបានបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិដែលជាមន្ត្រីជំនាញមកពីក្រសួងពាក់ព័ន្ធ និងបានបណ្តុះបណ្តាលមន្ត្រីជំនាញ នៃមន្ទីរវិស័យពាក់ព័ន្ធនៅខេត្តក្រចេះ សៀមរាប ស្ទឹងត្រែង និងខេត្តរតនគីរី។

**២. បញ្ហាប្រឈម** (Challenges)

- ការចុះឈ្មោះចូលរៀនរបស់កុមារអាយុ ៣ ឆ្នាំ ទៅ ៥ ឆ្នាំ គ្រប់រូបភាពនៅមានកម្រិត
- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធកម្មវិធីអប់រំកុមារតូច មិនទាន់ឆ្លើយតបទៅនឹងតម្រូវការ
- ការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា និងសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សាមិនទាន់បានពេញលេញ
- ការគាំពារ និងអភិវឌ្ឍកុមារតូចក្នុងវ័យ ១០០០ ថ្ងៃ ដំបូង មិនទាន់ត្រូវបានយកចិត្តទុកដាក់
- សមត្ថភាពបុគ្គលិកជំនាញនៅមិនទាន់ឆ្លើយតបតាមក្របខណ្ឌគុណភាពការអប់រំកុមារតូច
- វិបត្តបម្រែបម្រួលអាសធាតុ និងជាតិពុលក្នុងបរិយាកាសមានផលប៉ះពាល់ទៅលើការអភិវឌ្ឍកុមារតូច នៅមិនទាន់ទទួលបានការយកចិត្តទុកដាក់ខ្លាំងនៅឡើយ។

## ៣. ទិសដៅ៖

### ទស្សនៈវិស័យឆ្នាំ ២០២៣ (Vision for 2023)

- ជំរុញការប្រើប្រាស់កញ្ចប់អប់រំមាតាបិតាស្តីពីការចិញ្ចឹមបីបាច់កុមារតូចអោយបានទូលំទូលាយ
- បង្កើនការអនុវត្តផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចទៅថ្នាក់ក្រោមជាតិ រួមទាំងពង្រីកផែនការសកម្មភាពថ្នាក់ក្រោមជាតិ។
- ជំរុញការវិនិយោគលើការអភិវឌ្ឍកុមារតូចនៅថ្នាក់ក្រោមជាតិ តាមរយៈសមាហរណកម្មសកម្មភាព និងសេវាគាំពារ និងអភិវឌ្ឍកុមារតូចទៅក្នុងកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងសេវាអប់រំកុមារតូចគ្រប់រូបភាព រួមទាំងសមត្ថភាពអ្នកផ្តល់សេវា។

### ទស្សនៈវិស័យសម្រាប់ ២០២៤-២០២៨ (Vision for 2024-2028)

- បន្តលើកទឹកចិត្តអោយមានការវិនិយោគដល់ការអភិវឌ្ឍកុមារតូចនៅថ្នាក់ក្រោមជាតិ តាមរយៈការពង្រីកការធ្វើផែនការ ECCD នៅថ្នាក់ក្រោមជាតិ ដើម្បីការគាំពារ និងអភិវឌ្ឍកុមារតូច និងសមាហរណកម្មទៅក្នុងផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ពង្រីកសេវាអប់រំកុមារតូចនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ រួមបញ្ចូលទាំងការអប់រំពីការចិញ្ចឹមបីបាច់ថែទាំកុមារតូច ផ្សាភ្ជាប់សហគមន៍
- សហការរៀបចំឯកសារអប់រំឆ្លើយតបវិបត្តបម្រែបម្រួលអាសជាតុ និងជាតិពុលក្នុងបរិយាកាស ដែលនាំឱ្យប៉ះពាល់ទៅលើការអភិវឌ្ឍកុមារតូច
- ពង្រឹងគុណភាពសេវាអប់រំកុមារតូច ដោយផ្តោតលើកុមារត្រោមចូលរៀនបឋមសិក្សា
- ពង្រឹងយន្តការអនុវត្តក្នុងក្របខ័ណ្ឌគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូចឱ្យកាន់តែប្រសើរឡើង។

**Concept Note**
**On**
**Theme: Early Childhood Care and Development**

Investment in early years is a smart choice which provides optimal developoment to the child brain development, learning, health, attitude, and opportunities for lifelong success, all of which can be achieved through multi-sectoral interventions. Today, Climate Crisis is the child rights crisis, and air pollution has adverse impacts on health and brain development of children which requires immediate measures and actions against this crisis urgently thourhg multi-sectoral interventions to mitigate all possible negative effects on child development.

Reseach has shown that children develop their neuron connections rapidly druing their first 1000 days. Since conception until below three years of age is the critical time that parents need to provide adequate nutrition for the child brain to develop well as in this stage of life the child brain develops so quickly upto 70%. At the age of three the child brain develops upto 80% of adult brain, and upto 90% when they are reaching the age of 5 which predicts their cognitive development and other essential skills such as social skills, bravity, petience and communication skills which play important role to ensure the child future success.

**Nurturing Care Framework**

**The Nurturing Care Framework emphasizes that:**

- Rationale and reasons behind for the efforts to improve health, well-being, and human capital need to begin in the early years, from pregnancy to 3 years of age.
- Key challenges to the nurturing, education, and development of young children
- How to protect young children from the disastrous effects of negative factors and promote physical, mental, social and intellectual development
- Early childhood caregivers support mechanism to provide early childhood support services to achieve expected results.




The National Policy on Early Childhood Care and Deveopment has a vision "All Cambodian Children, from conception to aged under six, especially disadantaged, vulnerable and poor children, shall be provided with care and development services, in line with the Constitution of the Kingdom of Cambodia". The attedntion and early interventions to early years through early childhood care and development programme can reduce the child egocentrism such as: (1). I am the most improtant; (2). Everything is mine, (3). Everyone around me needs to pay attention to me; (4). Don't care and value others; and (5). Disobidience and stubon.

## 1. ECCD progress

**2010**
National Policy on Early Childhood Care and Development

**2013**
- Royal Decree on The Organization on Functioning of NC-ECCD
- Sub-Decree on Organization and Functioning of the General Secretariat for NC-ECCD

**2014**
National Action Plan for ECCD 2014-2018
- Offcial Launching Ceremony for National Policy and National Action Plan on ECCD

**2017**
- Asia-Pacific Internation Conference on ECD in Siem Reap

**2021**
Online Dissemination Workshop on Multi Sectoral support on ECCD for relevance's stakeholders in 25 provinces

**2022**
- Developed Naturing Care Parenting Pakeages in ECCD and Trained of The trainner
- Launching National Action Plan 2022-2026
- Developed NAP-ECCD in Kratie province

## Health and Nutrition:

Trend in the nutritional status of children




Trends in Child Mortality



**Children aged 5 received all forms of early childhood education:**




**key Progress in 2022:**

- **HE. Academician Dr. Hang Choun Naron**, the minister of education, Youth and Sports, and a chair of the National Committee on Early Childhood Care and Development gave speech in the opening of the Asia Pacific virtual conference on Early Childhood Development: Young Children in Crisis: Addressing the Impact of Covid-19, Climate Change and Environmental Degradation
- The National Action Plan on Early Childhood Develpment 2022-2026 was endorsed by the National Commitee on Early Childhood Care and Development in June
- Launched the National Action Plan on ECD 2022-26 for implementation with the participation of leaders and technical officiers of relevant institutions, the governors of the provinces/capital city, chairs of Provincial Consultative Commitee for Women and Children, and concerned technical officers from all provinces/capital city
- Launched the Provincial Action Plan on ECD 2023-25 of Kratie province
- Officially operatated four Community-based child care centers in Kampong Speu and continue Building five more centers in Kampong Cham province
- Participated as a key speaker to share experiences in virtual workshop on Integrated Early Childhood Development in Mongolia
- Participated as a key speaker in a vidual event "The Learning Exchange Forum on Southeast Asian Early Childhood Development Promotion (SEA-ECDP) and Workshop on Establishment of SEA–ECDP"
- Participated in the World Conference on ECCE in Uzbekistan
- Participated in International Conference on ECE, Child Care and Parenting in Indonesia
- Organized multisectoral study visit on ECD in Kratie province
- Developed Nurturing Care Parenting package, and trained the national master trainers from relevant ministries, and trained relevant technical officers from concerned provincial departments in Kratie, Siem Reap, Stung Treng and Rattanakiri provinces

**2. Challenges:**

- Enrollment of children aged 3-5 in all forms is still limited
- The expansion of insfrastructure for ECE programme still does not responde to the demands
- The implementation of preschool currículum and text books is still lacking
- Early Childhood Care and Development, especially in the first 1000 days to which is still not paid much attention

- The capacity of technical officers still not comply with quality early childhood education framewok
- Climate Change Crisis and air pollution which adversely impact child development have not been strongly paid attention

**3. Directions:**

**Vision for 2023**

- Promote the utilization of Nurturing Care Parenting Packaage more widely
- Improve the implementation of the National Action Plan on ECCD at sub-national levels, including the expansion of sub-national ECCD action plan development
- Encourage more investment on ECD at sub-national through Integration of activties and ECD services in Investment Programme and Development Plan at sub-national administrations
- Improve all forms of early childhood education, including the capacity of service providers

**Vision for 2024-2028**

- Continue encouraging the investments on ECD at sub-natioal through the expansion of sub-national ECD Action Plans, and Integration of ECD in Provincial/Capital City, District, and commune plans.
- Expand ECE services in públic institutions, including Nurturing Care Parenting with the linkage to communities
- Collaborate with development partners and other to develop educational materials in response to climate crisis and air pollution which impact on child development
- Strengthen ECE services, focusing on school readiness (preparedness before entering primary)
- Strengthen within the Framework of National Committee on ECD for better implemenation mechanisms